## ៣.៥ ការចូលរៀន និង សមធម៌នៅមធ្យមសិក្សាទុតិយភូមិ

### វត្ថុបំណង និង យុត្តិកម្ម

វត្ថុបំណងគោលនយោបាយនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ គឺត្រូវកែលំអការចូលរៀននៅមធ្យមសិក្សាទុតិយភូមិថ្នាក់ទី១០-១២ ឱ្យបាន ៣០០,០០០ នាក់នៅឆ្នាំ២០០៨។ យុទ្ធសាស្ត្ររបស់ក្រសួងអប់រំ យុវជន និងកីឡា គឺ បង្កើតសាលាមធ្យមសិក្សាទុតិយភូមិថ្មីនៅក្នុងស្រុកចំនួន៥២ ដែលបច្ចុប្បន្នពុំមានសាលារៀននេះ ទន្ទឹមនឹងការបង្កើតបណ្តាញសាលាមធ្យមសិក្សាទុតិយភូមិគំរូប្រកបដោយគុណភាពខ្ពស់នៅតាមខេត្ត-ក្រុង នីមួយៗ ដោយមានការអនុញ្ញាតឱ្យចូលរៀន ផ្អែកលើការសិក្សាល្អ ។

វត្ថុបំណងសំខាន់ៗនៃកម្មវិធីនេះ គឺត្រូវកែលំអការចូលរៀនដោយសមធម៌ និងប្រកបដោយគុណភាព នៅមធ្យមសិក្សាទុតិយភូមិ តាមរយៈការបង្កើនថវិកាដំណើរការសាលារៀនក្រីក្រទូទាំងប្រទេស។ វត្ថុបំណងទី២ គឺ បង្កើនចំនួនសិស្សប្រឡងជាប់ថ្នាក់ទី១២ ពីតំបន់ជនបទ និង តំបន់ដាច់ស្រយាល ដើម្បីជ្រើសរើសឱ្យចូលរៀននៅសាលាគរុកោសល្យ ឬនៅគ្រឹះស្ថានឧត្តមសិក្សា។ វត្ថុបំណងចុងក្រោយគឺ កែលំអតំលាភាពក្នុងការគ្រប់គ្រងថវិកាសាលារៀន តាមរយៈការបង្កើតក្រុមប្រឹក្សាភិបាល ដើម្បីគ្រប់គ្រងវិភាគទានស្ម័គ្រចិត្ត និង ស្របច្បាប់របស់សិស្សានុសិស្ស និងមាតាបិតាសិស្ស ។

### វិសាលភាព និង ភាពគ្របដណ្តប់

កម្មវិធីនេះ នឹងផ្តល់ថវិកាដំណើរការដល់សាលាមធ្យមសិក្សាទុតិយភូមិដែលមានបច្ចុប្បន្ន និង សាលាមធ្យមសិក្សាទុតិយភូមិបង្កើតថ្មី រួមទាំងសាលាមធ្យមសិក្សាទុតិយភូមិគំរូផងដែរ ។ ការចូលរៀនក្នុងសាលាមធ្យមសិក្សាទុតិយភូមិគំរូត្រូវផ្អែកលើលទ្ធផលប្រលងថ្នាក់ទី៩ និងលក្ខណៈវិនិច្ឆ័យផ្សេងៗទៀត ហើយសាលារៀនគំរូទាំងនោះនឹងទទួលបានថវិកាខុសពីសាលារៀនដទៃទៀត ដើម្បីរក្សាចីរភាពគុណភាពអប់រំខ្ពស់។ កម្មវិធីនេះក៏មានបំណងជួយកែលំអគុណភាពអប់រំ ដែលរួមមានការពង្រឹងប្រព័ន្ធប្រលងថ្នាក់ទី៩ និងទី១២ និងការចាប់ផ្តើមអនុវត្តស្តង់ដាអប្បបរមានៃលទ្ធផលសិក្សា ។ កម្មវិធីនេះនឹងចូលរួមចំណែកបន្ថែមទៀតដល់ការបង្កើនតម្លាភាព និងគណនេយ្យភាពរបស់សាលារៀន តាមរយៈការចាប់ផ្តើមអនុវត្តប្រព័ន្ធពិនិត្យតាមដានការបំពេញការងាររបស់សាលារៀន និងរបាយការណ៍ ។

កម្មវិធីនេះនឹងត្រូវបានបំពេញបន្ថែម ដោយកម្មវិធីអាហារូបករណ៍-ការលើកទឹកចិត្ត ដែលផ្តល់អាហារូបករណ៍ដល់សិស្សពូកែ ដើម្បីកាត់បន្ថយបន្ទុកចំណាយរបស់គ្រួសារក្រីក្រ។ កម្មវិធីនេះក៏ផ្សារភ្ជាប់ផងដែរទៅនឹងផែនការពង្រីកសំភាររូបវ័ន្ត ការអភិវឌ្ឍគ្រូបង្រៀន និងកំណែទម្រង់ការបណ្តុះបណ្តាល។

## សេចក្តីសង្ខេបសកម្មភាពសំខាន់ៗ

សកម្មភាពសំខាន់ៗនៃកម្មវិធីនេះ គឺផ្តល់ថវិកាដំណើការសាលារៀនតាមសន្ទស្សន៍ភាពក្រីក្រ ដល់សាលាមធ្យមសិក្សាទាំងអស់ ដែលជាដំបូងផ្តល់សំរាប់សំភារៈមូលដ្ឋាន និងការថែទាំសាលារៀនតាមសេចក្តីណែនាំដែលបានព្រមព្រៀងគ្នា។ រូបមន្តបែងចែកថវិកាដោយឡែកមួយនឹងត្រូវបង្កើតសំរាប់សាលាគំរូ និងសាលាមធ្យមសិក្សាទុតិយភូមិដែលនៅសេសសល់មួយចំនួនទៀត។ សេចក្តីណែនាំអំពីការចំណាយនឹងត្រូវកែលំអ ដើម្បីឆ្លើយតបនឹងស្ថានភាពរបស់សាលានីមួយៗនិងផ្តល់ភាពទន់ភ្លន់ក្នុងការសំរេចចិត្តចំណាយ ។សកម្មភាពទី២នឹងពង្រីកជាបន្តបន្ទាប់នូវកម្មវិធីពិសេសសំរាប់សិស្សពូកែ តាមរយៈការបង្រៀនតាមមុខវិជ្ជាឯកទេស និងការផ្តល់សំភារៈបង្រៀន ។

ប្រព័ន្ធកសាងផែនការហិរញ្ញវត្ថុ និងទទួលខុសត្រូវ លើថវិកាដំណើរការសាលារៀន នឹងចាប់ផ្តើមអនុវត្តនៅឆ្នាំ២០០៥ ដោយមានសេចក្តីណែនាំស្តីពីការចូលរួមក្នុងការគ្រប់គ្រង របស់មាតាបិតាសិស្ស និង សហគមន៍។ ទោះជាយ៉ាងណាក៏ដោយ ក្រសួងអប់រំ យុវជន និង កីឡា យល់ថាសេចក្តីណែនាំនេះមានសារៈសំខាន់ណាស់សំរាប់ធានាឱ្យសាលារៀនអាចធ្វើឱ្យមានតុល្យភាពរវាងការចំណាយលើសំភារៈការិយាល័យ ធនធានសំរាប់ការបង្រៀន និង បណ្ណាល័យ ការកែលំអហេដ្ឋារចនាសម្ព័ន្ធសាលារៀន (ដូចជា សង្ហារឹម អនាម័យ និងបរិស្ថាន) និងសកម្មភាពកីឡា សិល្បៈ កសិកម្ម និងផ្តោតការយកចិត្តទុកដាក់លើបំណិនជីវិត សំរាប់បង្ការទប់ស្កាត់មេរោគហ៊ីវ ជំងឺអេដស៍ និង បញ្ហាសុខភាពផ្សេងៗ។

កម្មវិធីនេះមានបំណងពង្រឹងសមត្ថភាពក្នុងការកសាងផែនការកម្មវិធី ការគ្រប់គ្រង និងការពិនិត្យតាមដាន ដើម្បីឆ្លើយតបទៅនឹងកំណើនសិស្សយ៉ាងឆាប់រហ័សតាមការគ្រោងទុក តាមរយៈការពង្រឹងប្រព័ន្ធពត៌មានគ្រប់គ្រងអប់រំមធ្យមសិក្សា ដើម្បីកំណត់អាទិភាពសំភាររូបវន្ត និងចំណាត់តាំងបុគ្គលិក ហើយនិងសមត្ថភាពរបស់មន្ត្រីថ្នាក់ខេត្ត-ក្រុង និងស្រុក-ខ័ណ្ឌឱ្យបានច្បាស់លាស់សំរាប់កែលំអសេវាអប់រំនៅក្នុងតំបន់ដែលពុំមានសេវាអប់រំគ្រប់គ្រាន់។ សកម្មភាពនេះនឹងពង្រឹងផងដែរនូវគំនិតផ្តួចផ្តើមទាំងឡាយ ដែលធានាដល់គុណភាពអប់រំ ជាពិសេសការប្រលងបញ្ចប់ភូមិសិក្សា អធិការកិច្ច និង ការអភិវឌ្ឍគ្រូបង្រៀន ។

## ការគ្រប់គ្រង និង ការពិនិត្យតាមដានកម្មវិធី

BMC រដ្ឋបាលកណ្តាល នៅក្នុងនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅបានរៀបចំរួចហើយសំរាប់កម្មវិធីនេះ។ ក្រសួង អប់រំ យុវជន និង កីឡា ក៏បានបង្កើត BMCs នៅគ្រប់មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត-ក្រុង និងការិយាល័យអប់រំ យុវជន និង កីឡាស្រុក-ខ័ណ្ឌ ដើម្បីគ្រប់គ្រងបំណែងចែកថវិកាដំណើរការសាលារៀន។ ក្រុមប្រឹក្សាភិបាលសាលារៀន/សហគមន៍ ត្រូវគ្រប់គ្រងមូលនិធិសំរាប់កម្មវិធីនេះ ដែលត្រូវបញ្ជូនតាមរយៈ BMCs ខេត្ត-ក្រុង ។ BMC នៅរដ្ឋបាលកណ្តាលទទួលខុសត្រូវរួមលើការគ្រប់គ្រង និងការពិនិត្យតាមដានកម្មវិធីនេះ។ ការគ្រប់គ្រង និងការពិនិត្យតាមដានបច្ចេកទេស និងហិរញ្ញវត្ថុរបស់កម្មវិធី ត្រូវផ្អែកតាមគោលការណ៏របស់

ក្រសួងអប់រំ យុវជន និង កីឡា ដែលបានឯកភាពគ្នាលើការពិនិត្យតាមដានប្រចាំត្រីមាស និងស្របតាមជំហានបើកផ្តល់សាច់ប្រាក់ដែលបានស្នើឡើង។ BMC មួយត្រូវបានបង្កើតនៅក្នុងនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅសំរាប់កម្មវិធីសិស្សពូកែ។

ការិយាល័យអប់រំ យុវជន និង កីឡាស្រុក-ខ័ណ្ឌ អធិការមធ្យមសិក្សា និងអ្នកគ្រប់គ្រងខេត្ត-ក្រុងទទួលខុសត្រូវលើការពិនិត្យតាមដានការរីកចំរើនជាប្រចាំ ដោយផ្អែកលើផែនការការងារ និងផែនការអភិវឌ្ឍន៍សាលារៀន។ បុគ្គលិក BMC នីមួយៗទទួលខុសត្រូវលើការពិនិត្យតាមដានភាពរីកចំរើននៃការចំណាយថវិកា។ BMC ខេត្ត-ក្រុងទទួលខុសត្រូវលើការពិនិត្យតាមដានការរីកចំរើន និងលទ្ធផលនៃសកម្មភាពផ្នែកបច្ចេកទេសរបស់កម្មវិធី ការផ្តល់ហិរញ្ញប្បទាន និង កែលំអកំហុសឆ្គងដែលចាំបាច់។ ក្រសួងអប់រំ យុវជន និង កីឡា នឹងពិនិត្យឡើងវិញ ថាតើយើងគួរផ្តល់ការទទួលខុសត្រូវឱ្យកាន់តែច្រើនដល់BMC ស្រុក-ខ័ណ្ឌដើម្បីធ្វើវិមជ្ឈការបន្ថែមទៀតចំពោះការអនុវត្តកម្មវិធី។ អគ្គនាយកដ្ឋានអប់រំនឹងរៀបចំគំរូតាងសវនកម្មបច្ចេកទេស ចំណែកឯអគ្គាធិការដ្ឋាននឹងរៀបចំគំរូតាងសវនកម្មហិរញ្ញវត្ថុផ្ទៃក្នុង ។

## ផែនការហិរញ្ញវត្ថុ

ការពង្រីកផែនការហិរញ្ញវត្ថុ ផ្អែកលើកំណើនសិស្សចូលរៀនដែលបានគ្រោងទុក ស្របគ្នានឹងការបង្កើនចំណាយសំរាប់សិស្សម្នាក់ ដើម្បីជាប្រយោជន៍ដល់ការកែលំអគុណភាពអប់រំ ។ តារាងខាងក្រោមសង្ខេបការចំណាយសំរាប់កម្មវិធី ។

*តារាង ៦ : ផែនការហិរញ្ញវត្ថុសំរាប់ការចូលរៀន និង ការបង្កើនគុណភាព ប្រសិទ្ធភាព នៅមធ្យមសិក្សាទុតិយភូមិ*

| សកម្មភាព | ចំណាយគិតជាលានរៀល | | | | |
|---|---|---|---|---|---|
| | 2004 | 2005 | 2006 | 2007 | 2008 |
| 1. ថវិកាដំណើរការសាលាមធ្យមសិក្សាទុតិយភូមិ/កញ្ចប់ថវិកា | 1,900 | 2,950 | 3,925 | 4,700 | 5,900 |
| 2. កម្មវិធីផ្តល់រង្វាន់សិស្សពូកែប្រចាំឆ្នាំ | 400 | 500 | 600 | 700 | 800 |
| 3. ការពង្រឹងការពិនិត្យតាមដាន | 200 | 250 | 275 | 300 | 300 |
| **ធនធាន : សរុប** | **2,500** | **3,700** | **4,800** | **5,700** | **7,000** |